**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ១៤១ សបណ.អគ

ថ្ងៃអង្គារ ៣ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់រយៈពេលអនុគ្រោះលើកលែងពិន័យអន្តរការណ៍ជាប្រាក់ ចំពោះអាជីវកម្មសេវាកម្មទេសចរណ៍

**យោង៖** - ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍

- ប្រកាសអន្តរក្រសួងលេខ ១៦០ សហវ.ប្រក.ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងទេសចរណ៍

ដោយស្ថានភាពវិបត្តិជំងឺកូវីដ១៩ (COVID-19) នៅពុំទាន់បានបញ្ចប់ និងដើម្បីចូលរួមសម្រួលដល់ការប្រកបធុរកិច្ចក្នុងវិស័យទេសចរណ៍កម្ពុជា ក្រសួងទេសចរណ៍ សូមជម្រាបជូនដល់ប្រតិបត្តិករទេសចរណ៍ទាំងអស់ឱ្យបានជ្រាបថា ក្រសួងទេសចរណ៍ សម្រេចផ្តល់រយៈពេលអនុគ្រោះលើកលែងពិន័យអន្តរការណ៍ជាប្រាក់ចំពោះការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ដែលជាសេវាសាធារណៈផ្តល់ដោយក្រសួងទេសចរណ៍ (ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១ កម្រងសេវាសាធារណៈរបស់រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ នៃប្រកាសអន្តរក្រសួងលេខ ១៦០ សហវ.ប្រក.ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងទេសចរណ៍) **ដោយអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬប្រតិបត្តិករទេសចរណ៍ ដែលពុំទាន់មានអាជ្ញាបណ្ណទេសចរណ៍ ឬអាជ្ញាបណ្ណទេសចរណ៍ហួសសុពលភាព ត្រូវរួសរាន់មកដាក់ពាក្យស្នើសុំថ្មី ឬបន្តអាជ្ញាបណ្ណទេសចរណ៍នៅក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំពោះព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់ក្រុមការងារអាជ្ញាបណ្ណទេសចរណ៍នៅទីស្តីការក្រសួងទេសចរណ៍ ឬតាមរយៈលេខទូរសព្ទ ០៨៩ ៧៦៧ ៦៦៤ ឬ ០៩២ ៧៧៩ ៨៣៣ ឬ ០១១ ៨៣៣ ៣១៨។

ទទួលបានសេចក្តីជូនដំណឹងនេះ សូម ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬប្រតិបត្តិករទេសចរណ៍ទាំងអស់អនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យបានរួសរាន់ និងប្រកបដោយស្មារតីទទួលខុសត្រូវ។

**ក្រសួងទេសចរណ៍**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- សមាគមក្នុងវិស័យឧស្សាហកម្មទេសចរណ៍កម្ពុជា
- ឯកសារ កាលប្បវត្តិ

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧០ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org